# រឿងរាជគហទារិកា

(ចាកវិ.ខុ.)

( គុណនៃការប្រគេននំ ដល់ព្រះមោគ្គល្លាន )

កាល ព្រះសម្ពុទ្ធបរមគ្រូគង់នៅក្នុងវត្តវេឡុវន នាក្រុងរាជគ្រឹះ ។ កាលនោះមាន នាងទារិកាម្នាក់ នៅក្នុងក្រុងរាជគ្រឹះជាកូនរបស់ឧបដ្ឋាកព្រះមហាមោគ្គល្លាន ។ នាងនោះជាស្ត្រី មានសទ្ធាមាំក្នុងព្រះពុទ្ធសាសនា ដល់អាយុ១៦ឆ្នាំ មាតាបិតា បានរៀបឲ្យមានស្វាមី ហើយបញ្ជូនឲ្យទៅនៅខាងសំណាក់មាតាបិតាក្មេក ។

ឯមាតាបិតាក្មេកនោះ ជាមនុស្សមិច្ឆាទិដ្ឋិ មានចិត្តរឹងរូសមិនជ្រះថ្លា ក្នុងព្រះពុទ្ធសាសនាឡើយ ។ ថ្ងៃមួយព្រះមហាមោគ្គល្លាន និមន្តទៅបិណ្ឌបាត្រក្នុងភូមិនោះ នាងកូនប្រសារបានឃើញក៏ចុះ ទៅនិមន្តឲ្យឈប់នៅមុខផ្ទះរបស់ខ្លួន ទើបនាង ទៅប្រាប់ដល់ម្តាយក្មេក ៗ នោះធ្វើជាមិនឮ គេចចុះពីផ្ទះបាត់ទៅ ។ នាងដឹង ហេតុនោះហើយ គិតពិចារណាថាក្នុងផ្ទះ នេះមានតែវត្ថុអ្វីល្មមប្រគេនលោក មាន តែនំមួយដែលអ្នកម្តាយទុកពិសា ក៏យកនំនោះទៅកាត់ជាពីរចំណែក មួយចំ ណែកទុកជូនម្តាយ មួយចំណែកយកទៅប្រគេនព្រះមហាមោគ្គល្លាន ៗ ធ្វើភត្តា នុមោទនាហើយ ក៏និមន្តបាត់ទៅ ។

ម្តាយក្មេកបានឃើញព្រះមហាមោគ្គល្លាន និមន្តទៅផុតហើយ ក៏ឡើងទៅលើ ផ្ទះ ។ នាងទេរិកាក៏ចូលទៅអង្គុយបត់ជើងលើកដៃ ប្រណម្យជូនបុណ្យដែលបាន ប្រគេននំនោះដល់ម្តាយក្មេក ៗ ខឹងណាស់ក្រឡេកមើលទៅគៀនជញ្ជាំងឃើញ អង្រៃមួយ ក៏ចាប់អង្រៃនោះសំពងកូនប្រសា ត្រូវត្រង់ចង្អួយស្មា ស្លាប់ក្នុងពេល នោះទៅ ។

កូនប្រសារនោះបានកើតទៅក្នុងស្ថានតាវតឹង្ស បានឃើញនាងទេពធីតាស្ថិតនៅ ក្នុងវិមានមាស មានស្រីទេពអប្សរកំពុង ចោររោមបំរើ លោកក៏និមន្តទៅក្បែរវិមាន នោះ ។ នាងទេពធីតាឃើញហើយមានសេចក្តីត្រេកអរណាស់ នឹកថាព្រះថេរៈ នេះហើយដែលបានសង្គ្រោះដល់អញក្នុងជាតិមុន ក៏នាំបរិវារចុះទៅថ្វាយបង្គំ ។

ព្រះមហាមោគ្គល្លាន មានថេរៈដីកាថាសួរប្រវត្តិរបស់នាង ៗ បានរៀបរាប់ប្រគេន ដោយសព្វគ្រប់ លោកក៏និមន្តមកស្ថានមនុស្សវិញ នាំដំណឹងនោះទៅក្រាបទូល

ដល់ព្រះមានព្រះភាគ ។ ទ្រង់ប្រារព្ធរឿងនោះឲ្យជាហេតុហើយ ក៏សំដែងនូវ
អានិសង្សរបស់ទានជាភិយ្យោភាពក្នុងពេលនោះ ។

សូមអស់លោកអ្នកអនុមោទនា !

ចប់